អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបង្កើតចង្វាក់ភ្លេងតាមកូនកាស**

**ចិត្តចលភាព** ៖ បំណិនចលនាធំ៖

ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំតូចនិងសាច់ដុំធំ

**សិក្សាសង្គម** ៖ ចម្រៀង និងតន្ត្រី៖ ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិតនិងបទពិសោធន៍ផ្នែកតន្ត្រី

**ភាសាខ្មែរ** ៖ ការស្គាល់តួអក្សរ៖ ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

ប្រាប់បានពីរបៀបដើរ រត់ វារ លូន លោត ចុះនិងឡើង បោះ តោង ឡើង គប់ ប្រមៀល បង្វិលខ្លួន រុញ និងទាញ ទៅតាមគោលដៅ និងចម្ងាយដែលបានកំណត់។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារនានា តាមចង្វាក់ភ្លេង។

បំណិនសម្បទា៖ ទះដៃបន្ទរ គោះសម្ភារនានាតាមចង្វាក់ភ្លេង។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ប្រាប់បានពីសូរសំឡេងសត្វឬវត្ថុនានានៅក្នុងបរិស្ថាន

បំណិនសម្បទា៖ បង្ហាញពីភាពខុសគ្នានៃសូរសំឡេង

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កូនកាសដែលមានសញ្ញាជាចង្វាក់ភ្លេងនីមួយៗដែលធ្វើពីដៃ ខ្លួនប្រាណ ជើង ឬមាត់ជាដើម (កូនកាសមាន២ឈុត ក្នុងមួយឈុតអាចមានប្រមាណជា៧មុខ មួយមុខមាន២សន្លឹកដូចគ្នា សរុប១៤សន្លឹក) មានដូចជា៖ **ទះដៃ ទះភ្លៅ ទះទ្រូង តន្រ្តំជើងម្ខាង លោតតន្រ្តំជើងទាំងពីរ ខ្សឹបជាមួយមាត់ ទះគូទជាដើម**

**ការរៀបចំ** ៖

អ្នកគ្រូត្រូវត្រៀមកូនកាសអោយបានរួចរាល់ទាំងពីរឈុតមុននឹងត្រូវនាំកុមារលេងល្បែងសកម្មភាពមួយនេះ និងមួយទៀត គ្រូត្រូវច្បាស់ក្នុងការលេងល្បែងជាមុនសិនផងដែរ។

**សេចក្តីណែនាំ** ៖

1. ដំបូងសួរកុមារពីឧបករណ៍តន្រ្តីជាមុនសិន ថាតើកុមារស្គាល់វាបានប៉ុន្មាន?
2. តើកុមារចូលចិត្តឧបករណ៍មួយណាជាងគេ? តើមានអ្វីខ្លះ? អោយកុមាររៀបរាប់ប្រាប់ជាមុនសិន

3. និយាយទៀតថា តើកូនៗចេះធ្វើចង្វាក់ភ្លេងជាមួយដៃ ជើង ខ្លួនប្រាណដែរឬទេ កូនៗចង់លេងអត់? បន្តិចទៀតនេះយើងនឹងលេងល្បែងមួយ ដែលយើងនឹងនាំគ្នាបង្កើតជាចង្វាក់ភ្លេងជាមួយដៃ ជើង ខ្លួនប្រាណទាំងអស់គ្នា។
4. គ្រូចាប់ផ្តើមប្រាប់និងពន្យល់កុមារពីរបៀបលេងល្បែងនេះជាមុនសិន
    - ➔ អ្នកគ្រូបង្ហាញឬធ្វើកាយវិការតាមកូនកាសឱ្យកុមារបានមើលសិនជាមុនសិន និងឱ្យកុមារធ្វើតាមគ្រូផងដែរ។
    - ➔ កុមារទាំងអស់ត្រូវនៅកន្លែងរបស់ខ្លួនរៀងៗខ្លួន
    - ➔ គ្រូតំរៀបកូនកាសទាំងអស់នៅខាងមុខ
    - ➔ ចាប់ផ្តើមលេង គ្រូធ្វើជាចង្វាក់ភ្លេងជាមួយនឹងការទះដៃ ឬតន្រ្តំជើង ឬខ្យល់តាមមាត់ ឬទះគូទ ទៅតាមកូនកាសដែលមាននៅក្នុងកូនកាសដែលបានរៀបចំ។
      (បញ្ជាក់ ធ្វើតិចឬច្រើនអាស្រ័យលើកម្រិតរបស់កុមាររបស់អ្នក)
    - ➔ គ្រូធ្វើ១ដងឬ២ដង តាមចិត្តគ្រូ បន្ទាប់មក គ្រូហៅកុមារណាម្នាក់ឡើងទៅរើសកូនកាសដែលគ្រូបានធ្វើមុនហ្នឹង រួចបិទវានៅលើក្តារខៀន
    - ➔ បន្ទាប់មក កុមារម្នាក់នោះធ្វើកាយវិការដូចរូបកូនកាសដែលបានបិទ និងឱ្យកុមារផ្សេងទៀតដែលនៅក្នុងថ្នាក់ធ្វើកាយវិការតាមគេជាការស្រេច។

**ការប្រែប្រួល**

- ★ ល្បែងនេះអាចលេងបានច្រើនបែបណាស់ មិនថាជាក្រុម ឬទាំងអស់គ្នា ឬក្រុមធំ និងផ្សេងៗទៀត
- ★ របៀបលេងខាងលើគ្រាន់តែជាឧទាហរណ៍មួយបែបសម្រាប់អ្នកក្នុងការលេងល្បែងសកម្មភាពមួយនេះ
- ★ អ្នកអាចលេងបែបនេះបានគឺ លេងបែបកុមារម្នាក់ឡើងមកលេង ចាប់យកកូនកាសមួយសន្លឹក និងធ្វើកាយវិការតាមកូនកាសនោះ បន្ទាប់មកអោយកុមារទាំងអស់ដែលនៅកន្លែងធ្វើតាមកុមារម្នាក់នោះ។
- ★ ឬ ចែកកុមារជាក្រុមដែលមានសមាជិក៥ឬ៦នាក់ បន្ទាប់មកលេងម្តង១ក្រុម។ ក្រុមមួយឡើងទៅខាងលើ ចាប់យកកូនកាសម្នាក់១សន្លឹកៗ បន្ទាប់មកតំរៀបគ្នានិងដាក់កូនកាសនៅពីមុខពួកគេ ហើយចាប់ផ្តើមធ្វើចង្វាក់ភ្លេងតាមកូនកាសដែលខ្លួនបានចាប់បាននោះជាការស្រេច។
- ★ និងមានវិធីសាស្រ្តផ្សេងទៀតជាច្រើន អ្នកអាចគិតពីវាបានដោយខ្លួនឯងផងដែរ។